**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្ដារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Nov-2012, 15:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យធ្វើសវនាការជាសាធារណៈ លើបណ្ដឹងសាទុក្ខផ្សេងៗ ជំទាស់នឹងសេចក្ដីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង០០២/០១ ឬសំណើមួយទៀតសុំដាក់ចម្លើយតបរួមទៅនឹងចម្លើយតបទាំង៣របស់មេធាវីការពារក្ដី**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រឹម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សេរីវុឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Florence Ndepele MUMBA
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន
Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## សំណើ

១- កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខភ្លាមៗមួយ ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង០០២/០១[1] (បណ្តឹងសាទុក្ខ)។ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើមួយសុំពន្យារពេលដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខនេះ ក្នុងរយៈពេលចំនួន១៥ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងអំពីការបកប្រែជាភាសាបារាំង[2]។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តី អៀង សារី និង នួន ជា បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹង បណ្តឹងសាទុក្ខនេះ[3]។

២- នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី ខៀវ សំផន ពន្យារពេលដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខនេះ ចំនួន១០ថ្ងៃ។ ការពន្យារពេលនេះ គឺត្រូវចាប់ផ្តើមបន្ទាប់ពីមានការជូនដំណឹងអំពីការបកប្រែជាភាសាបារាំង[4]។

៣- មាត្រា៨(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក[5] បានណែនាំថា ភាគីនានាត្រូវបានអនុញ្ញាតឲ្យដាក់ចម្លើយតបទៅនឹងសារណាតប ក្នុងករណីមិនមានអំណះអំណាងដោយផ្ទាល់មាត់ ដែលក្នុងករណីណាក៏ដោយ ត្រូវដាក់ឯកសារក្នុងរយៈពេល៥ថ្ងៃបន្ទាប់ពីការជូនដំណឹងនៃចម្លើយតប។ ក្នុងករណីនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសុំឲ្យបើកសវនាការសួរដេញដោលផ្ទាល់មាត់លើបណ្តឹងសាទុក្ខនេះ ដោយសារតែសារៈសំខាន់នៃបញ្ហាទាំងនេះបានលើកឡើងដល់គ្រប់ភាគី និងប្រជាជនកម្ពុជា។

---

[1] ឯកសារលេខ **E163/5/1**, ការចុះបណ្តឹងសាទុក្ខ - បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១, ថ្ងៃទី៨ វិច្ឆិកា ២០១២។

[2] ឯកសារលេខ **E163/5/1/2**, Demande urgente de prorogation de délai de réponse, ថ្ងៃទី១៣ វិច្ឆិកា ២០១២។

[3] ឯកសារលេខ **E163/5/1/3**, ចម្លើយតបរបស់ អៀង សារី ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១, ថ្ងៃទី១៩ វិច្ឆិកា ២០១២។

[4] ឯកសារលេខ **E163/5/1/2/1** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១, ថ្ងៃទី២០ វិច្ឆិកា ២០១២។

[5] ឯកសារលេខ **ECCC/01/2007/Rev:7**, សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក។

៤- ប្រសិនបើអំណះអំណាងផ្ទាល់មាត់បែបនេះមិនតម្រូវដោយអង្គជំនុំជម្រះទេ សហព្រះរាជអាជ្ញាស្នើថា ខ្លួនគួរត្រូវបានអនុញ្ញាតឱ្យដាក់ចម្លើយតបរួមមួយទៅនឹងសារណាតបទាំងបី របស់មេធាវីការពារក្តី ដោយចាប់ផ្តើមក្នុងរយៈពេលប្រាំថ្ងៃគិតចាប់ពីថ្ងៃដាក់សារណាតបរបស់ ខៀវ សំផន ជាភាសាខ្មែរ និងជាភាសាមួយទៀតក្នុងចំណោមភាសាផ្លូវការពីររបស់ អវតក។ ការណ៍នេះនឹងជៀសវាងបាននូវការដាក់សារណាច្រំដែលលើបញ្ហាដដែលៗ ហើយនឹងជួយសន្សំសំចៃការចំណាយពេលវេលាដោយមិនចាំបាច់ក្នុងការពង្រាង និងបកប្រែចម្លើយតបលើបណ្តឹងឧទ្ធរណ៍ទាំងបីនេះដាច់ពីគ្នា។

៥- ចំពោះពេលវេលាខ្លី ដើម្បីឆ្លើយតបទៅនឹងសារណាតបបច្ចុប្បន្នរបស់ អៀង សារី និង នួន ជា នោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើនេះត្រូវសម្រេច នៅក្នុងរយៈពេលមួយថ្ងៃ ទៅពីរថ្ងៃនេះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] Cayley QC |